គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

# សេចក្តីជូនដំណឹង

គណៈកម្មាធិការ ខុមហ្វ្រែល មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា គណៈកម្មាធិការ ខុមហ្វ្រែល នឹងរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតស្តីពី "**ការកំណត់តម្រូវការជាអាទិភាពនៅឃុំ សង្កាត់ដាច់ស្រយាល**" ចំនួន ០៩ នៅតាមទីកន្លែងដោយឡែកៗពីគ្នា។

សិក្ខាសាលានេះ មានគោលបំណង បង្កើនការយល់ដឹងដល់ម្ចាស់ឆ្នោតអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងបង្កើនឱកាសឱ្យម្ចាស់ឆ្នោតចូលរួមក្នុងការពិភាក្សាដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ សង្កាត់របស់ខ្លួន ហើយតម្រូវការជាអាទិភាពទាំងនេះ នឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាម ងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សក្នុងឃុំ។

ខុមហ្វ្រែល នឹងអញ្ជើញវាគ្មិនជាក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងតំណាងអង្គការសង្គមស៊ីវិល ឬប្រធានសហគមន៍ដើម្បីចាប់អារម្មណ៍ទៅលើតម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ដែលបានលើកឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ សម្រាប់ផ្តល់ជូនគណបក្សនយោបាយ និងមន្ត្រីជាប់ឆ្នោតបំពេញ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញាតំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

## ទីកន្លែង និងកាលបរិច្ឆេទ សិក្ខាសាលាសម្លេងម្ចាស់ឆ្នោត

| ល.រ | ថ្ងៃខែឆ្នាំរៀបចំ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | រាជធានី/ខេត្ត | ឈ្មោះទំនាក់ទំនង | ទូរសព្ទ |
|---|---|---|---|---|---|---|
| ១ | ៧/០៧/២០១១ | ក្រាំងស្គារ | ទឹកផុស | កំពង់ឆ្នាំង | លោក លាភ ម៉ុនលាង | ០១២ ៣៤២ ៤១៧ |
| ២ | ២១/០៧/២០១១ | ផ្លូវទឹក | កំពង់លែង | | | |
| ៣ | ១១/០៧/២០១១ | ស្រែណូយ | វ៉ារិន | សៀមរាប | លោក ផល ម៉ុនត | ០៩២ ៦៧៦ ៩៨១ |
| ៤ | ១២/០៧/២០១១ | បឹងបេង | ម៉ាឡៃ | បន្ទាយមានជ័យ | លោក យុត ថងឌី | ០៩៧ ៧៥៥៥ ៥៨០៥ |
| ៥ | ១៥/០៧/២០១១ | សំបួរ | មង្គលបុរី | | | |
| ៦ | ១២/០៧/២០១១ | ឈើតុំ | ក្រគរ | ពោធិសាត់ | អ្នកស្រី មិន មុន្នីជាត | ០៩៧ ៦៨៤៤ ៤៦៨ |
| ៧ | ១៥/០៧/២០១១ | កោះជីវាំង | ឯកភ្នំ | បាត់ដំបង | លោក យិន ម៉េងលី | ០១២ ៩៧០ ៨២៣ |

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។
Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | ២៨/០៧/២០១១ | បេង | បន្ទាយអំពិល | ឧត្តមានជ័យ | **លោក ចៅ ឌុទ្ធី** | **០១២ ៥៦៣ ៥៩៨** |
| ៩ | ២៩/០៧/២០១១ | កំពង់រាប | ព្រែកប្បាស | តាកែវ | **អ្នកស្រី សេខ សុទ្ធារី** | **០១២ ៨៩២ ៤៨៦** |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់ !*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ ២០១១*

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖** លោកស្រី ៖ **ហេង សុគន្ធា** (០១៧ ៥៨៣ ៨៦៩)

**បេសកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។